00384848

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
05 / 10 / 2015
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/71

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / OCT / 2009
ម៉ោង (Time/Heure): 08:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Uy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>**
**<u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"</u>**
**<u>សាធារណៈ</u>**

# សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
# ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី ៦៦

រៀបចំដោយ: **សែ គុលវុឌ្ឍី** និង Natacha WEXELS-RISER

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Matteo Crippa, លោកស្រី សែ គុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Anees Ahmed, លោក តាន់ សេណារ៉ុង, លោក ប៉ាក់ ចន្ទលីណូ, លោក ពេជ្រ សម្បត្តិ, លោក ហ្សួត វិចិត្រ, លោក ទី មុនិន្ទ, កញ្ញា Madeleine Arens (ព្រឹក) |

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្កេចអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោកការ សាវុត្ថ, លោក François Roux, លោក ចាន់ រ៉ាវុធ, លោកស្រី Heleyn Unac, លោក Alexandre Prezati, កញ្ញា Lucile Nattiez |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Christine Martineau, លោក Alain Werner កញ្ញា ទី ស្រ៊ីនណា(ព្រឹក) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Scott Bywater, លោកស្រី Julie Massé, លោក សាន គីរី, លោក មៀច សុវណ្ណា |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖ ១២.១៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៥.០៥ | បញ្ចប់ម៉ោង៖១៥.២០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ១៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការទទួលស្គាល់មេធាវីអន្តរជាតិ Christine Martineau តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១(ជំនួសឲ្យមេធាវីតំណាងក្រុមទី៣) អង្គជំនុំជម្រះ | ៩.១១ | ៩.១៤ |
| ការជូនដំណឹងទាក់ទងនឹងសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ | ៩.១៥ | ៩.១៦ |
| ការជូនដំណឹងស្តីពីកាលបរិច្ឆេទសវនាការ | អង្គជំនុំជម្រះ | ៩.១៦ | ៩.១៩ |
| ការស្នើសុំអានសេចក្តីថ្លែងការណ៍របស់ | មេធាវីការពារក្តី | ៩.២០ | ៩.២៣ |

| | | | |
|---|---|---|---|
| សាស្ត្រាចារ្យ Henry King និងបង្ហាញចេញពីខ្សែវីដេអូខ្លី និងសំណើសុំបន្ថែមពេលវេលាសម្រាប់អ្នកជំនាញ Raoul Marc Jennar | | | |
| ការធ្វើសម្បថរបស់អ្នកជំនាញ François Sironi Guilbaud និង ការ ស៊ុនបូណាត | អង្គជំនុំជម្រះ | ៩.២៦ | ៩.៣៤ |
| ការធ្វើសេចក្ដីថ្លែងការណ៍របស់អ្នកជំនាញ ការស៊ុនបូណាត និងលោកស្រី François Sironi Guilbaud | អង្គជំនុំជម្រះ | ៩.៣៤ | ១៣.៥០ |
| ការតាំងសំណួរទៅអ្នកជំនាញ លោក ការ ស៊ុនបូណាត និងលោកស្រី François Sironi Guilbaud | សហព្រះរាជអាជ្ញា | ១៣.៥១ | ១៥.៣១ |
| ការស្នើសុំឲ្យអង្គជំនុំជម្រះជូនដំណឹងទៅអ្នកជំនាញអំពីមូលហេតុនៃការអវត្តមានដើមបណ្ដឹងរដ្ឋប្បវេណី និងមិនមានការតាំងសំណួរទៅអ្នកជំនាញ ដោយដើមបណ្ដឹងរដ្ឋប្បវេណី | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១ និង ៣ | ១៥.៣២ | ១៥.៣៨ |
| ការតាំងសំណួរទៅអ្នកជំនាញ លោក ការ ស៊ុនបូណាត និងលោកស្រី François Sironi Guilbaud | មេធាវីការពារក្ដី | ១៥.៣៨ | ១៦.១៥ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**ការទទួលស្គាល់មេធាវីអន្តរជាតិ** Christine Martineau **តំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៣**

អង្គជំនុំជម្រះបានទទួលស្គាល់លោកស្រី Christine Martineau ជាមេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៣ ។

**ការជូនដំណឹងទាក់ទងនឹងសកម្មភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១ បានចង្អុលបង្ហាញថាដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណី

មិនយល់ទៅនឹងសេចក្តីសម្រេចដែល មិនអនុញ្ញាតិឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរទៅជនជាប់ចោទ និងសាក្សីបញ្ជាក់ពីអត្តចរិតរបស់ជនជាប់ចោទនោះ ពួកគេសម្រេចមិនចូលរួមនៅក្នុងសវនាការថ្ងៃនេះទេ។

**ការជូនដំណឹងអំពីកាលវិភាគសវនាការដែលគ្រោងធ្វើនៅថ្ងៃបន្តបន្ទាប់**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីកាលវិភាគសវនាការដែលគ្រោងនឹងធ្វើនៅថ្ងៃបន្តបន្ទាប់ទៀត (សូមមើលខាងក្រោម)

**សំណើសុំអានសេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ** Henry T.King **និងបង្ហាញចេញពីខ្សែវីដេអូ និងសំណើសុំពេលវេលាបន្ថែមសម្រាប់អ្នកជំនាញ** Raoul Marc Jennar

មេធាវីការពារក្តីបានស្នើសុំអង្គជំនុំជម្រះក្នុងការអាននូវសេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ Henry T.King នៅពេលសវនាការ និងបង្ហាញនៅក្នុងតុលាការ អំពីការជំនុំជម្រះករណី Obrenovic ដែលយកចេញពីខ្សែវីដេអូ។ មេធាវីការពារក្តីក៏បានស្នើសុំផងដែរនូវពេលវេលាបន្ថែមបើករណីចាំបាច់ សម្រាប់ការធ្វើសក្ខីកម្មរបស់អ្នកជំនាញ Raoul Marc Jennar ។

**ការធ្វើសម្បថរបស់អ្នកជំនាញ ការ ស៊ុនបូណាត និងលោកស្រី** François Sironi-Guilbaud

អ្នកជំនាញទាំងពីររូបបានធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។

**ការធ្វើសេចក្តីថ្លែងការណ៍ដោយអ្នកជំនាញ ការ ស៊ុនបូណាត និងលោកស្រី** François Sironi-Guilbaud

អង្គជំនុំជម្រះបានសួរពីភាពជំនាញ និងទទួលស្គាល់ពីភាពជំនាញរបស់លោក ការ ស៊ុនបូណាត និងលោកស្រី François Sironi-Guilbaud ហើយបានតាំងសំណួរទៅពួកគេទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ។

សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីបានតាំងសំណួរទៅអ្នកជំនាញទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់អជសដ | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត,សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E3/509 | B1/IV | របាយការណ៍ចិត្តសាស្ត្ររបស់អ្នកជំនាញ ការ ស៊ុន បូណាត និង François Sironi-Guilbaud | សាធារណៈ | 00210946-00211081<br>00211082-00211151<br>00177506-00177576<br>របាយកាណ៍នេះនឹងត្រូវចេញជាមួយ និង ប្រតិចារឹកក្រោយពីការកែតម្រូវភេទរបស់កូនជនជាប់ចោទ និងចំនួនការស្លាប់ ដែលជនជាប់ចោទគិតថាមាននៅស២១ |

<u>**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**</u>

១-សេចក្តីសម្រេចទាក់ទងនឹងកាលវិភាគសវនាការ

នៅថ្ងៃនេះអង្គជំនុំជម្រះនឹងស្តាប់នៅបទបង្ហាញរបស់អ្នកជំនាញចំនួនពីររូប ដែលនឹងផ្តល់សក្ខីកម្មរួមគ្នា។ ដំបូងអ្នកជំនាញទាំងពីរនឹងសង្ខេបនូវរបាយការណ៍របស់គាត់ ដែលបានធ្វើនៅក្នុងដំណាក់កាលស៊ើបអង្កេត បន្ទាប់មកនឹងធ្វើបច្ចុប្បន្នភាពនៃរបាយការណ៍របស់គាត់។ បន្ទាប់មកទៀតការតាំងសំណួរដល់អ្នកជំនាញទាំងពីរចាប់ផ្តើម ដូចដែលបានចង្អុលបង្ហាញនៅក្នុងតារាងដែលភ្ជាប់មកជាមួយ ។

ដោយសារកាលវិភាគនៃសវនាការបានកំណត់ច្បាស់លាស់ អង្គជំនុំជម្រះបានសម្រេចថានឹងស្តាប់សក្ខីកម្មរបស់សាក្សី D1, D2, D3, D4, D5 និង D6 ដូចដែលបានគ្រោងកោះហៅសម្រាប់សប្តាហ៍រួចមកហើយ បន្ទាប់ពីផ្តល់សក្ខីកម្មរបស់អ្នកជំនាញទាំងពីររូប ។

ប្រសិនបើការផ្តល់សក្ខីកម្ម ដែលបានគ្រោងរួចហើយសម្រាប់សប្តាហ៍ក្រោយបញ្ចប់មុនពេលកំណត់

00384853



អង្គជំនុំជម្រះនឹងបន្តសួរសំណួរដល់ជនជាប់ចោទទាក់ទងទៅនឹងអត្តចរិតរបស់គាត់ ។

ប្រសិនបើមានពេលសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី អាចសួរសំណួរដល់ជនជាប់ចោទទាក់ទងទៅនឹងអត្តចរិតរបស់គាត់បាននៅពេលនោះ ។

នៅថ្ងៃទី១៤,១៥ ខែកញ្ញា ឆ្នាំ២០០៩ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់អ្នកជំនាញ និងសាក្សី Richard Goldstone, Raoul Marc Jennar, Christopher Lapel, D8 និង Stéphane Hessel ។

នៅថ្ងៃទី១៦ ខែកញ្ញា គឺពេញមួយថ្ងៃ និងថ្ងៃទី១៧ ខែកញ្ញា សម្រាប់ពេលព្រឹកអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ប្រសិនបើមានពេលគ្រប់គ្រាន់នឹងបញ្ចប់ការសួរសំណួរដល់ជនជាប់ចោទអំពីអត្តចរិតរបស់គាត់ ។ ហើយបន្ទាប់មកអង្គជំនុំជម្រះនឹងពិភាក្សាបញ្ហាអំពីដំណើរការនីតិវិធីដូចជាការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះផ្អែកតាមវិធាន៨៧ ។ ប្រសិនបើសវនាការមិនអាចបញ្ចប់តាមកាលវិភាគដែលបានគ្រោងទុក សវនាការនឹងលើកបន្តនៅថ្ងៃទី២២ ខែកញ្ញា ឬចាំបាច់ត្រូវបន្តរហូតដល់ថ្ងៃទី២៣ ខែកញ្ញា ។

២-បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកសវនាការវិញនៅថ្ងៃអង្គារ ទី០១ ខែកញ្ញា ឆ្នាំ២០០៩ ។

<u>ឱកាសសម្រាប់ការលើកវារកាលសវនាការ</u>

ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី០១ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។ SKV Nun

ភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលវុទ្ធី Natacha WEXELS-RISER